**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៧ សណន**

# សេចក្ដីណែនាំរបស់រាជរដ្ឋាភិបាល
# ស្ដីពី
# ការត្រៀមបង្ការដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទឹកជំនន់

រាជរដ្ឋាភិបាល សូមជម្រាបជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋ នៅទូទាំងប្រទេសឲ្យបានជ្រាបថា៖ យោងតាមការសង្កេតតាមដាន និងព្យាករណ៍អាកាសធាតុ ដែលបានបង្ហាញដោយក្រសួងធនធានទឹក និងឧតុនិយម ឥទ្ធិពលរបស់ប្រព័ន្ធសម្ពាធទាបមកលើព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យមានភ្លៀងធ្លាក់ជាបន្តបន្ទាប់ ដែលធ្វើឲ្យខេត្តមួយចំនួនកំពុងរងឥទ្ធិពលទឹកភ្លៀង ដូចជា ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ប្រឈមនិងការជន់លិច។ ដោយឡែកតំបន់ផ្ទៃរងទឹកភ្លៀងរបស់ទន្លេមេគង្គ ក្នុងប្រទេសឡាវ និងប្រទេសថៃ ក៏មានភ្លៀង ធ្លាក់ច្រើនបង្កឲ្យទឹកទន្លេមេគង្គហក់ឡើងផងដែរ។

ដោយយោងលើកត្តាអាកាសធាតុ និងមាត្រា ២ ជំពូក១ នៃច្បាប់ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី រាជធានី ខេត្ត ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ត្រូវបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវមានការរៀបចំទុកជាមុន ដោយប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប នៅពេលមានទឹកជំនន់កើតឡើង ត្រូវជម្លៀសប្រជាពលរដ្ឋទៅកាន់ទីទួលសុវត្ថិភាព បញ្ចៀសឲ្យខាងតែបាន នូវការប៉ះពាល់ដល់អាយុជីវិត និងការខូចខាតផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**